អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១១

## សេចក្តីប្រកាសព័ត៌មាន

## សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ នឹងប្រព្រឹត្តទៅពីថ្ងៃទី២៨ ដល់ ៣១ ខែមីនា ឆ្នាំ២០១១

អង្គជំនុំជម្រះតុលាការកំពូលនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងដំណើរការសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ប្រឆាំងលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច តាមកាលវិភាគដូចខាងក្រោម៖

**ថ្ងៃច័ន្ទ ទី២៨ ខែមីនា ឆ្នាំ២០១១**

ម៉ោង ០៩:០០ - ១៦:៣០ សវនាការវគ្គទី១ (យុត្តាធិការលើបុគ្គល)

**ថ្ងៃអង្គារ ទី២៩ ខែមីនា ឆ្នាំ២០១១**

ម៉ោង ០៩:០០ - ១៦:៣០ សវនាការវគ្គទី២ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)
និងសវនាការវគ្គទី៣ (ការកំណត់ទោស)

**ថ្ងៃពុធ ទី៣០ ខែមីនា ឆ្នាំ២០១១**

ម៉ោង ០៩:០០ - ១៦:៣០ សវនាការវគ្គទី៤ (បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី)

ប្រសិនបើសវនាការមិនអាចបញ្ចប់ក្នុងអំឡុងពេលដែលបានកំណត់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលនឹងបន្តសវនាការនៅថ្ងៃព្រហស្បតិ៍ ទី៣១ ខែមីនា។

កាលវិភាគលម្អិតជាងនេះអាចរកបាននៅក្នុងឧបសម្ព័ន្ធនៃដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខដែលទាញយកពីគេហទំព័រ៖ http://www.eccc.gov.kh/khmer/cabinet/courtDoc/921/F20.1_KH.pdf

កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះសាលាដំបូង ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងត្រូវផ្តន្ទាទោសកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឲ្យជាប់ពន្ធនាគាររយៈពេល ៣៥ឆ្នាំ។ រយៈពេលនេះត្រូវបានកាត់បន្ថយ៥ឆ្នាំ ជាការទូទាត់សងចំពោះរយៈពេលដែលជនត្រូវចោទត្រូវបានឃុំឃាំងមិនស្របច្បាប់ដោយតុលាការយោធានៃព្រះរាជាណាចក្រកម្ពុជាមុនពេលគាត់ត្រូវបានបញ្ជូនមក អ.វ.ត.ក។

អង្គជំនុំជម្រះតុលាការកំពូលនឹងកាត់សេចក្ដីលើបណ្ដឹងសាទុក្ខដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។

សារណាបណ្ដឹងសាទុក្ខសង្ខេបរបស់សហព្រះរាជអាជ្ញាមាននៅ៖
http://www.eccc.gov.kh/khmer/cabinet/courtDoc/718/F10_KH.pdf

សារណាបណ្ដឹងសាទុក្ខសង្ខេបរបស់ជនជាប់ចោទមាននៅ៖
http://www.eccc.gov.kh/khmer/cabinet/courtDoc/741/F14_KH.pdf

សារណាបណ្ដឹងសាទុក្ខសង្ខេបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមាននៅ៖
http://www.eccc.gov.kh/khmer/cabinet/courtDoc/727/F11_KH.pdf
http://www.eccc.gov.kh/khmer/cabinet/courtDoc/738/F13_KH[1].pdf
http://www.eccc.gov.kh/khmer/cabinet/courtDoc/639/F8_KH.pdf
http://www.eccc.gov.kh/khmer/cabinet/courtDoc/913/F12_KH.pdf
http://www.eccc.gov.kh/khmer/cabinet/courtDoc/716/F9_KH.pdf

**ប័ណ្ណព័ត៌មានសម្រាប់ចូលស្ដាប់សវនាការបណ្ដឹងសាទុក្ខ៖**

តំណាងសារព័ត៌មានត្រូវតែចុះឈ្មោះជាមុន ប្រសិនបើមានបំណងចូលរួមតាមដានសវនាការបណ្ដឹងសាទុក្ខ ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១។ តំណាងសារព័ត៌មានត្រូវបំពេញតាមលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម៖

ក) តំណាងសារព័ត៌មានដែលកំពុងកាន់ប័ណ្ណព័ត៌មានចេញដោយ អ.វ.ត.ក និងដែលនៅមានសុពលភាពនៅឡើយ ត្រូវតែសុំអនុញ្ញាតចូលរួមក្នុងសវនាការ ដោយផ្ញើរសារអេឡិកត្រូនិកមកផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក តាមអាស័យដ្ឋាន PAS@ECCC.GOV.KH។

ខ) តំណាងសារព័ត៌មានដែលកំពុងកាន់ប័ណ្ណព័ត៌មានចេញដោយ អ.វ.ត.ក ប៉ុន្តែអស់សុពលភាព ត្រូវតែបំពេញនិងចុះហត្ថលេខាលើពាក្យសុំធ្វើប័ណ្ណព័ត៌មាន ដែលអាចទាញយកបានពីគេហទំព័រនេះ (http://www.eccc.gov.kh/english/cabinet/file Upload/26/ECCC_Accreditation_Media_Application_Form.doc) រួចផ្ញើរមក PAS@ECCC.GOV.KH. ជាមួយនឹងសំណើសុំធ្វើប័ណ្ណសារព័ត៌មាន។ សូមបញ្ជាក់លេខកាតចាស់ផង។

គ) តំណាងសារព័ត៌មានដែលពុំធ្លាប់បានទទួលប័ណ្ណសារព័ត៌មានចេញដោយ អ.វ.ត.ក ត្រូវតែបំពេញពាក្យសុំដែលអាចទាញយកបានពីគេហទំព័រនេះ (http://www.eccc.gov.kh/english/cabinet/fileUpload/26/ECCC_Accreditation_ Media_Application_Form.doc) និងចុះហត្ថលេខាត្រឹមត្រូវ ព្រមទាំងភ្ជាប់ជាមួយនូវរូបថតបិទកាតមួយសន្លឹក និងច្បាប់ចម្លងនៃលិខិតឆ្លងដែន រួមផ្ញើរមក PAS@ECCC.GOV.KH។

**កាលបរិច្ឆេទចុងក្រោយសម្រាប់ការចុះឈ្មោះគឺ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១។**